**ស៊ុម សុរិយា**

**ផ្ញើជូនពី ៖** ហង់ វណ្ណៈ <Hang.Vannak@eccc.gov.kh>

**កាលបរិច្ឆេទផ្ញើ ៖** ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ៧:០៣ នាទីល្ងាច

**ផ្ញើជូន ៖** កែវ សុធា, ស៊ុម សុរិយា

**កម្មវត្ថុ ៖** សំណើរបស់ខ្ញុំសម្រាប់មុខងារដែលនៅសេសសល់

**ការសម្គាល់ការតាមដានបន្ត ៖** ការសម្គាល់សម្រាប់ការតាមដានបន្ត

**ស្ថានភាពនៃការសម្គាល់ ៖** ត្រូវបានសម្គាល់

សូមគោរពជូនលោកទាំងពីរជាទីរាប់អាន

ខ្ញុំសរសេរអ៊ីមែលនេះដើម្បីស្នើឱ្យមានការផ្តោតលើមនុស្ស ២ ក្រុមដែលសមនឹងទទួលបានការយកចិត្តទុកដាក់នាពេលអនាគត បន្ទាប់ពី អ.វ.ត.ក បិទដំណើរការ។

ខ្ញុំបានត្រឹមតែផ្ញើជូននូវគំនិតនេះតាមអ៊ីមែលប៉ុណ្ណោះ ព្រោះខ្ញុំពុំមានពេលវេលាក្នុងការសរសេររៀបរាប់ជាលិខិតផ្លូវការទេ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់

វណ្ណៈ

---

**<u>១. សាក្សី និងអ្នកផ្តល់សក្ខីកម្ម</u>**

ក្នុងដំណើរការសវនាការក្នុងបន្ទប់សវនាការ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនត្រូវបានអញ្ជើញឱ្យមកផ្តល់សក្ខីកម្ម ហើយតាមដែលខ្ញុំដឹង សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនមិនទទួលបានវិធានការការពារអ្វីឡើយ។ ក្រោយការផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ពួកគាត់បានត្រឡប់ទៅរស់នៅក្នុងសហគមន៍ជាធម្មតា ដោយរំពឹងថានឹងគ្មានអ្វីកើតឡើងចំពោះពួកគាត់ និងរំពឹងថា ពួកគាត់នឹងត្រូវបានការពារដោយច្បាប់ និងអាជ្ញាធរ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនរស់នៅក្នុងភូមិតែមួយជាមួយអតីតកម្មាភិបាលខ្មែរក្រហម។

ទោះជាយ៉ាងណាក៏ដោយ នៅពេលគ្មាន អ.វ.ត.ក ខ្ញុំយល់ថា ពួកគាត់ប្រហែលជាគ្មានអារម្មណ៍កក់ក្តៅឡើយ ហើយការិយាល័យទទួលបន្ទុកមុខងារដែលនៅសេសសល់ គួរខិតខំដោះស្រាយបញ្ហានេះយ៉ាងប្រុងប្រយ័ត្ន។

ថ្មីៗនេះ ខ្ញុំបានទទួលព័ត៌មានមួយចំនួនថា ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ កំពុងប្រឈមនឹងការមាក់ងាយក្នុងភូមិរបស់ពួកគេ។

**២.ដើមបណ្តឹងរដ្ឋប្បវេណី**

ផ្អែកតាមសាវតា (ប្រហែលក្នុងឆ្នាំ២០០៩) នៅដំណាក់កាលដំបូង មានមនុស្សមិនច្រើនទេដែលចង់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬដើមបណ្តឹង ព្រោះពួកគាត់ព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានប្រាប់ខ្ញុំថា នៅពេលអង្គភាពគាំពារជនរងគ្រោះអញ្ជើញឱ្យពួកគាត់ចូលរួមសវនាការ ឬវេទិកាក្នុងទីក្រុងភ្នំពេញ ពួកគាត់បានប្រាប់អ្នកជិតខាងថា ពួកគាត់ទៅលេងសាច់ញាតិ ហើយនៅពេលខ្ញុំសួរថាតើហេតុអ្វីពួកគាត់ធ្វើដូច្នេះ ពួកគាត់បានប្រាប់ខ្ញុំវិញថា ពួកគាត់មានការព្រួយបារម្ភ ព្រោះអតីតកម្មាភិបាលខ្មែរក្រហមមួយចំនួន រស់នៅក្នុង ឬជិតភូមិរបស់ពួកគាត់។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ខ្ញុំបានចុះតាមភូមិដើម្បីពិនិត្យគម្រោងនានា។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននៅតែប្រាប់ខ្ញុំថា ពួកគាត់ចេះតែព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ព្រោះ អ.វ.ត.ក មានភាពស្ងៀមស្ងាត់ និងមិនសូវសកម្មដូចមុន។ ពួកគាត់ប្រាប់ខ្ញុំទៀតថា ពួកគាត់ចាត់ទុកខ្លួនឯងជាក្រុមជនជាតិភាគតិច ព្រោះពួកគាត់ស្ថិតក្នុងចំណោមមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងចំណោមប្រជាជនរាប់រយនាក់ដែលរស់នៅក្នុងភូមិរបស់ពួកគាត់។